ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.........................................................

# សុន្ទរកថា

## លោកជំទាវបណ្ឌិត ជា សិរី ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងឱកាសបិទសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការសន្ទស្សន៍ថ្លៃលំនៅដ្ឋាន

សណ្ឋាគារ Raffles Hotel Le Royal

ថ្ងៃចន្ទ ៧កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២

**សូមគោរព ៖**

- **លោកជំទាវ ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ
- **លោក Yasuhisa Ojima** តំណាង IMF ប្រចាំកម្ពុជា
- **លោកស្រី Vanda Guerreiro** អ្នកជំនាញការស្ថិតិសន្ទស្សន៍ថ្លៃលំនៅដ្ឋាន
- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញាទាំងអស់ជាទីមេត្រី!

សិក្ខាសាលាស្តីពីការផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការសន្ទស្សន៍ថ្លៃលំនៅដ្ឋាន ដែលចំណាយពេលពេញមួយព្រឹកនេះ បានឈានដល់ទីបញ្ចប់ ប្រកបដោយជោគជ័យនិងផ្លែផ្កា។ តាមរយៈការធ្វើបទឧទ្ទេសនាមពីមន្ត្រីជំនាញនាយកដ្ឋានស្ថិតិ នៃធនាគារជាតិនៃកម្ពុជា ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកនាងកញ្ញា បានជ្រួតជ្រាបពីសារៈសំខាន់នៃស្ថិតិនេះ និងបានស្វែងយល់ពីដំណើរការនៃការរៀបចំចងក្រងស្ថិតិសន្ទស្សន៍ថ្លៃលំនៅដ្ឋាន ចាប់តាំងពីជំហានដំបូងរហូតដល់ទទួលបានលទ្ធផលចុងក្រោយ ដោយចាប់ផ្តើមពីការស្វែងរកប្រភពទិន្នន័យ ការរៀបចំតារាងទិន្នន័យ ការរៀបចំឯកសារណែនាំនិងសេចក្តីពន្យល់សម្រាប់អ្នករាយការណ៍ ការវាយតម្លៃទិន្នន័យទទួលបាន ការជ្រើសរើសវិធីសាស្ត្រចងក្រង និងការវិភាគលទ្ធផល ជាដើម។

ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវស្ថិតិសន្ទស្សន៍ថ្លៃលំនៅដ្ឋានក្នុងថ្ងៃនេះ ជាការបង្ហាញវឌ្ឍមានសូចនាករថ្មីបន្ថែមទៀត ដែលនឹងដើរតួនាទីយ៉ាងសំខាន់ និងជាគ្រឿងផ្សំដ៏ចាំបាច់ក្នុងការតាមដាន និងវាយតម្លៃប្រកបដោយប្រសិទ្ធភាពនូវស្ថានភាព និងហានិភ័យនៃវិស័យអចលនទ្រព្យមកលើសេដ្ឋកិច្ច ពិសេសវិស័យហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ដើម្បីបង្កើនគុណភាពស្ថិតិសន្ទស្សន៍ថ្លៃលំនៅដ្ឋានឱ្យកាន់តែប្រសើរ និងមានវិសាលភាពគ្របដណ្តប់តាមបណ្តាខេត្ត-ក្រុងនៅក្នុងប្រទេសកម្ពុជា ចាំបាច់ត្រូវមានការចូលរួមបន្ថែមទៀតពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងការពង្រឹងគុណភាពនៃរបាយការណ៍ឱ្យបានពេញលេញ និងមានសុក្រឹតភាព។

លើសពីនេះ បើទោះជាការចងក្រងស្ថិតិ RPPI សម្រេចបានផ្លែផ្កាជាទីមោទនៈក្តី ការវិភាគឱ្យបានគ្រប់ជ្រុងជ្រោយនិងស៊ីជម្រៅលើវិស័យសំណង់និងអចលនទ្រព្យនៅតែទាមទារឱ្យមានព័ត៌មាននិងទិន្នន័យបន្ថែម ដែលមានប្រភពពីក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអង្គភាពវិស័យឯកជនផងដែរ។ ព័ត៌មាននិងទិន្នន័យសំខាន់ៗសម្រាប់បម្រើដល់ការវិភាគដូចជា ប្រភពទុនសម្រាប់បម្រើដល់ការសាងសង់ ប្រភេទសំណង់ ចំនួនគម្រោងសាងសង់ ស្ថានភាពជួញដូរអចលនទ្រព្យ វិនិយោគិន ចំណូលពន្ធលើអចលនទ្រព្យ ការផ្គត់ផ្គង់ប្រចាំឆ្នាំ តម្រូវការក្នុងស្រុកនិងក្រៅប្រទេស។ល។ ក្នុងន័យនេះ ការចូលរួមសហការពីគ្រប់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និងវិស័យឯកជនពាក់ព័ន្ធក្នុងការចែករំលែកនូវរាល់ទិន្នន័យពាក់ព័ន្ធ ដើម្បីឱ្យការវិភាគស៊ីជម្រៅគ្របដណ្តប់គ្រប់ទិដ្ឋភាពនៃវិស័យអចលនទ្រព្យទាំងមូល។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

សិក្ខាសាលាព្រឹកនេះបានឈានដល់ទីបញ្ចប់ប្រកបដោយជោគជ័យ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា** ដែលមានវត្តមានក្នុងសិក្ខាសាលាដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ Zoom ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមសិក្ខាសាលាផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការសន្ទស្សន៍ថ្លៃលំនៅដ្ឋាននាពេលនេះ។ ទន្ទឹមនេះ ខ្ញុំក៏សូមកោតសរសើរដល់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអង្គភាពវិស័យឯកជនមួយចំនួន ដែលតែងតែសហការផ្តល់ទិន្នន័យជាប្រចាំមកកាន់ធនាគារជាតិនៃកម្ពុជា មិនត្រឹមតែសម្រាប់ផលិតស្ថិតិសន្ទស្សន៍ថ្លៃលំនៅដ្ឋាន

ប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់បម្រើដល់ការចងក្រងស្ថិតិម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសំខាន់មួយចំនួន ដូចជា ស្ថិតិជញ្ជីងទូទាត់ និងស្ថិតិរូបិយវត្ថុនិងហិរញ្ញវត្ថុ សម្រាប់បម្រើដល់ការវិភាគ និងការរៀបចំគោលនយោបាយរូបិយវត្ថុ ស្ថិរភាពហិរញ្ញវត្ថុ និងបទប្បញ្ញត្តិប្រុងប្រយ័ត្នសម្រាប់ប្រព័ន្ធធនាគារនាពេលកន្លងមក។ ជាមួយគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ IMF និងប្រទេសម្ចាស់ជំនួយទាំង៩ ដែលបានជួយគាំទ្រគម្រោងកម្មវិធីជំនួយបច្ចេកទេស "មូលនិធិទិន្នន័យសម្រាប់ការសម្រេចចិត្ត (Data for Decision Fund-D4D)" តាំងពីដើមរៀងមក។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ គណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ឱ្យជួបប្រទះតែពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបិទសិក្ខាសាលាស្តីពីការផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការសន្ទស្សន៍ថ្លៃលំនៅដ្ឋាន ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**